សកម្មភាព ៖ **ល្បែងពិពណ៌នា**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ(អំពីរាងកាយផ្ទាល់ខ្លួន)

**ភាសាខ្មែរ**

ការសន្ទនា(សន្ទនាដោយប្រើពាក្យ ឬ ឃ្លាត្រូវតាមវ័យ ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

អំណត់ ព្យាយាម ស្វាហាប់ រហ័សរហួន និងសប្បាយរីករាយ។

ធ្វើចលនាម្រាមដៃដោយទប់ លំនឹងតាមទម្រង់ផ្សេងៗនៃ សកម្មភាពណាមួយ។

**(វិទ្យាសាស្ត្រ)** ប្រាប់ឈ្មោះអំពីរាងកាយរបស់មនុស្សឱ្យបាន ។

បង្ហាញពីមុខងាររាងកាយមនុស្ស ភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្តាប់ មាត់សម្រាប់ញ៉ាំ ឬនិយាយ។

ប្រុងប្រយ័ត្ន និងថែរក្សាសុខភាពផ្នែកផ្សេងៗនៃរាងកាយ។

**(ភាសាខ្មែរ)** ប្រាប់បានពីព័ត៌មានផ្ទាល់ខ្លួន ឬ ព្រឹត្តិការណ៍ផ្សេងៗដែលបានជួបប្រទះតាមលំដាប់លំដោយនៃសាច់រឿង។

រៀបរាប់ពីព័ត៌មានផ្ទាល់ខ្លួន ឬ ព្រឹត្តិការណ៍ផ្សេងៗដែលបានជួបតាមលំដាប់លំដោយសាច់រឿងទៅមិត្តភក្តិ ឬ មនុស្សធំ។ សួរសំណួរ និងទទួលបានព័ត៌មានត្រឡប់ពីអ្នកដ៏ទៃ។

សប្បាយរីករាយក្នុងការសន្ទនាតាមការណែនាំ។

ឥរិយាបទសមរម្យ រង់ចាំវេននិយាយ និងចូលរួមក្នុងការសន្ទនា។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "កុមារគំរូ "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ រៀបចំសំណួរជាមុនអំពីមុខ រូបរាងមនុស្ស

**ការរៀបចំ** ៖ គូររូបនៅលើក្ដាខៀន

**សេក្ដីណែនាំ៖**

1. ប្រាប់ក្មេងៗថា៖ ថ្ងៃនេះលោកគ្រូ/អ្នកគ្រូនឹងលេង**ល្បែងពិពណ៌នា**ជាមួយកូនៗទាំងអស់គ្នា។
2. គូររង្វង់មុខមនុស្សនៅលើកក្ដារខៀនជាមុនសិន។
3. សួរកូនៗទាំងអស់គ្នាថា ៖
   - ☐ តើមនុស្សយើងមានមាត់ប៉ុន្មាន? - ចាស/បាទ មានមាត់ ១
   - ☐ មានភ្នែកប៉ុន្មាន? - ចាស/បាទ មានភ្នែក ២
   - ☐ មានច្រមុះប៉ុន្មាន…? - ចាស/បាទ មានច្រមុះ ១
4. គូររូបតាមការឆ្លើយរបស់ក្មេងៗនៅក្នុងរង្វង់មុខ រហូតចេញជាមុខមាត់មនុស្ស ឬ រូបរាងមនុស្សក៏បានដែរ។
5. សួររហូតទាល់តែគ្រប់គ្នា ហើយនិយាយថា អូ! គ្រូក៏មានមុខមាត់ដូចកូនៗដែរ។
6. សួរក្មេងៗបន្តទៀតថា ប្រសិនបើពួកយើងមានភ្នែក២ដូចគ្នា ច្រមុះ១ដូចគ្នាដែរ តើកូនៗគួរតែប្រាប់ទៅមិត្តរួមថ្នាក់ផ្សេងទៀតយ៉ាងដូចម្ដេច? - បាទ/ចាស ខ្ញុំមានច្រមុះមួយ ភ្នែក២ មាត់មួយ ច្រចៀក២ ដូចអ្នកដែរ។
7. ប្រាប់ក្មេងៗថា កូនៗដឹងទេថាមនុស្សយើងមានលក្ខណៈសម្បត្តិដូចគ្នា តែមានចំណុចពិសេសផ្សេងៗពីគ្នា។ មានអ្នកខ្លះមើលទៅដូចគ្នាបេះបិទតែម្ដង។ តែកូនៗខ្លះមានចិញ្ចើមក្រាស រោមភ្នែកខ្មៅ ចង្ការវែងខ្លី និងថ្ពាល់រលោង ប៉ោង… ។
8. ចាប់ផ្ដើមឱ្យក្មេងម្នាក់ពិពណ៌នាសាកល្បងពីមិត្តរួមថ្នាក់ម្នាក់ដោយប្រើពាក្យគួរសមដូចជា៖ ភេទ (ប្រុស ឬ ស្រី) សក់វែង សក់ខ្លី សក់ត្រង់ សក់រួញ ធាត់ ស្គម និងមុខរាងផ្លែល្ហុង… ។
9. បន្ទាប់មកពន្យល់ពីការលេង**ល្បែងពិពណ៌នា**នោះតែម្ដង…

- ក្មេងៗទាំងអស់ ត្រូវក្រោកឈរនៅពីមុខអ្នកគ្រូទាំងអស់គ្នា
- ហៅក្មេងម្នាក់ឡើងទៅខាងមុខ

- អ្នកគ្រូត្រូវខ្សឹបប្រាប់ក្មេងឱ្យនិយាយពិពណ៌នាមុខមាត់ រូបរាងបុគ្គលិកលក្ខណៈពីមិត្តរួមថ្នាក់ណាម្នាក់ នៅខាងមុខ ដោយប្រើពាក្យសមរម្យ ។
- បន្ទាប់មកប្រាប់ឱ្យក្មេងៗទាយថា តើក្មេងម្នាក់ណាដែលមិត្តបានពិពណ៌នានោះ?
- បើពិពណ៌នាទៅមិត្តរួមថ្នាក់ពិបាកយល់ អាចពិពណ៌នាពីអ្វីផ្សេងទៀតដែលបុគ្គលនោះចូលចិត្តធ្វើ និងប្រសិនបើពួកគេពូកែខាងអ្វី?
- ជៀសវាងការនិយាយពាក្យថា ‹ទេ ខុសហើយ› ប្រសិនបើក្មេងៗទាយខុសពីគោលដៅរបស់អ្នកពិពណ៌នា។ ឧទាហរណ៍៖ គាត់ចូលចិត្តអានសៀវភៅ ចូលចិត្តច្រៀង ចូលចិត្តយំជាងគេ….។
- ត្រូវរំលឹកក្មេងៗថាត្រូវប្រើពាក្យគួរសម នៅពេលដែលពិពណ៌នាពីនរណាម្នាក់ ។

**ការប្រែប្រួល៖**

សម្គាល់៖ ល្បែងនេះ អ្នកអាចលេងដោយឱ្យក្មេងៗពិពណ៌នាពីរាងកាយរបស់មនុស្ស ផ្លែឈើ សត្វ បន្លែ ឬ វត្ថុផ្សេងៗក៏បានដែរ។